# រាជរដ្ឋាភិបាលកម្ពុជា

# ផែនការជាតិ

## កតិកាសញ្ញាពិភពលោកស្តីពីទេសន្តរប្រវេសន៍ ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់

## ២០២៤ - ២០២៦

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
(គ.ជ.ប.ជ)

United Nations
Network on Migration
Working Better Together

# សេចក្តីសង្ខេប

កតិកាសញ្ញាពិភពលោកស្តីពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ (GCM) ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨ (Resolution A/RES/73/195)។ កតិកាសញ្ញានេះផ្អែកលើគោលការណ៍ណែនាំចំនួន១០ លើកកម្ពស់វិធីសាស្ត្រផ្តោតលើតម្រូវការគ្រប់វិស័យ ដើម្បីដោះស្រាយបញ្ហាទេសន្តរប្រវេសន៍ ដែលទាមទារឱ្យមានការចូលរួមពីគ្រប់លំដាប់ថ្នាក់នៃស្ថាប័នជាតិ សហជីពពាណិជ្ជកម្ម វិស័យឯកជន អង្គការសង្គមស៊ីវិល និងអង្គការសហប្រជាជាតិ។ គោលការណ៍ទាំងនេះត្រូវបានឆ្លុះបញ្ចាំងតាមរយៈគោលបំណងចំនួន២៣ របស់កតិកាសញ្ញា ដែលប្រទេសនីមួយៗត្រូវបានជំរុញលើកទឹកចិត្តអនុវត្តតាមរយៈផែនការជាតិ (កថាខណ្ឌ ៥៣)។

អនុលោមតាមកតិកាសញ្ញាពិភពលោកស្តីពីទេសន្តរប្រវេសន៍ វេទិកាវាយតម្លៃទេសន្តរប្រវេសន៍អន្តរជាតិ (IMRF)[1] បាន និងកំពុងដើរតួនាទីជាវេទិកាអន្តររដ្ឋាភិបាលចំបងមួយសម្រាប់ពិភាក្សា ផ្លាស់ប្តូរបទពិសោធន៍ និងវាយតម្លៃការអនុវត្តគោលបំណងទាំង២៣របស់ GCM នៅថ្នាក់សកល។ វេទិកាវាយតម្លៃទេសន្តរប្រវេសន៍អន្តរជាតិនឹងត្រូវរៀបចំឡើងរៀងរាល់បួនឆ្នាំម្តង ហើយជាលទ្ធផលនឹងមានសេចក្តីប្រកាសរបាយការណ៍អំពីវឌ្ឍនភាពអន្តររដ្ឋាភិបាលនៅក្នុងវេទិកានីមួយៗ។ វេទិកាវាយតម្លៃទេសន្តរប្រវេសន៍អន្តរជាតិលើកទី១ ត្រូវបានរៀបចំឡើងនៅខែឧសភា ឆ្នាំ២០២២។

តាមរយៈការអនុម័តកតិកាសញ្ញានេះ រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាអនុវត្តនូវគោលបំណងទាំង២៣ ដែលបានកំណត់នៅក្នុងកតិកាសញ្ញានេះ។ ដោយឡែក រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានកំណត់យកគោលបំណងអាទិភាពចំនួនបី ដើម្បីអនុវត្តក្នុងជំហានដំបូង ដោយមានការឯកភាពពីក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ព្រមទាំងបានសហការរៀបចំសេចក្តីព្រាងនៃផែនការជាតិនេះ ដោយអនុលោមតាមគោលការណ៍ណែនាំរបស់កតិកាសញ្ញា។ ផែនការជាតិបង្កើតឡើងតាមរយៈការរៀបចំសិក្ខាសាលាពិគ្រោះយោបល់ជាច្រើន ដើម្បីប្រមូលធាតុចូលបន្ថែមពីអង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិ បណ្តាញអង្គការសហប្រជាជាតិស្តីពីទេសន្តរប្រវេសន៍ និងអង្គការសង្គមស៊ីវិល។ ក្នុងនាមជាប្រទេសគាំទ្រកតិកាសញ្ញាតាំងពីចាប់ផ្តើមដំបូង កម្ពុជាក៏ជាប្រទេសមួយក្នុងអាស៊ីអាគ្នេយ៍ ដែល

[1] International Migration Review Forum, IMRF

ប្តេជ្ញាចិត្តចូលរួមអនុវត្តកតិកាសញ្ញានេះ ក្នុងចំណោមប្រទេស១៨ដំបូង ដែលត្រូវបានទទួលស្គាល់ពីបណ្តាញអង្គការសហប្រជាជាតិស្តីពីទេសន្តរប្រវេសន៍[2] ថាជាប្រទេសឈានមុខក្នុងការអនុវត្តគំនិតផ្តួចផ្តើមនៃកតិកាសញ្ញាពិភពលោក[3] ហើយនឹងមានឱកាសផ្តល់នូវបទពិសោធន៍ ចំណេះដឹង និងការអនុវត្តល្អៗសម្រាប់ប្រទេសដទៃទៀត។

## គោលបំណងអាទិភាព

នៅក្នុងឆ្នាំ២០២០ និងឆ្នាំ២០២១ គោលបំណងជាអាទិភាពទាំងបីនៃកតិកាសញ្ញា ត្រូវបានជ្រើសរើសដោយមានការឯកភាពពីអន្តរក្រសួង ស្ថាប័នក្នុងរាជរដ្ឋាភិបាលកម្ពុជា និងមានការឯកភាពពីនាយករដ្ឋមន្ត្រី សម្រាប់អនុវត្តសាកល្បងក្នុងរយៈពេលពីរឆ្នាំដំបូងបន្ទាប់ពីការអនុម័ត។ ការជ្រើសរើសទាំងនេះត្រូវបានធ្វើឡើងយ៉ាងយកចិត្តទុកដាក់ ផ្តោតលើបញ្ហាចម្បងៗដែលក្រសួង ស្ថាប័នពាក់ព័ន្ធនានា បាន និងកំពុងយកចិត្តទុកដាក់ដោះស្រាយ។ ផែនការជាតិសម្រាប់បន្តអនុវត្តកតិកាសញ្ញារយៈពេលពីរឆ្នាំបន្ទាប់ត្រូវបានបង្កើតឡើងក្រោមការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលនឹងត្រូវធ្វើការពិនិត្យ តាមដាន និងវាយតម្លៃលើសមិទ្ធផលនៃការអនុវត្ត ដើម្បីឆ្លើយតបទៅនឹងគោលដៅនៃផែនការនេះ។ ការប្តេជ្ញាចិត្តនេះត្រូវបានបង្ហាញក្នុងកិច្ចប្រជុំ IMRF លើកទី១នាឆ្នាំ២០២២ ហើយនឹងបន្តជំរុញការអនុវត្តក្នុងដំណាក់កាលទី១នៅចុងឆ្នាំ២០២៤។

ជម្រើសគោលបំណងអាទិភាពទាំងបី គឺដោយផ្អែកលើការទទួលស្គាល់តម្រូវការក្នុងការប្រមូលទិន្នន័យជាប្រព័ន្ធនិងសុក្រឹត ស្តីពីទេសន្តរប្រវេសន៍ សម្រាប់រៀបចំគោលនយោបាយផ្អែកលើភស្តុតាង តម្រូវការក្នុងការគ្រប់គ្រងព្រំដែនប្រកបដោយការទទួលខុសត្រូវរវាងប្រទេសជាប់ព្រំដែនជាមួយគ្នា និងតម្រូវការបង្កើនកិច្ចសហប្រតិបត្តិការអន្តរជាតិ សម្រាប់ពង្រឹងដំណើរការគ្រប់គ្រងទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់។ គោលបំណងអាទិភាពទាំងបីនោះគឺៈ

**គោលបំណងទី១.** ប្រមូលនិងប្រើប្រាស់ជាមូលដ្ឋាននូវទិន្នន័យដែលសុក្រឹត និងបែងចែកតាមប្រភេទ សម្រាប់ការរៀបចំគោលនយោបាយផ្អែកលើភស្តុតាង

[2] United Nations Network on Migration, UNNM
[3] Champion Country of GCM Initiative

**គោលបំណងទី១១.** គ្រប់គ្រងព្រំដែនរួមគ្នា ដោយសុវត្ថិភាព និងស៊ីសង្វាក់គ្នា និង

**គោលបំណងទី២៣.** ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងភាពជាដៃគូសកល សម្រាប់ទេសន្តរប្រវេសន៍ ប្រកបដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់។

អាទិភាពដែលត្រូវអនុវត្តក្នុងរយៈពេលពីរឆ្នាំដំបូង សម្រាប់**គោលបំណងទី១** រួមមានអាទិភាពស្នូលចំនួនប្រាំ គឺ (១) ពង្រឹងកិច្ចសហការរវាងក្រសួងនានា និងធនធានរដ្ឋ ដែលទទួលខុសត្រូវទិន្នន័យផ្សេងៗ ទាក់ទងនឹងទេសន្តរប្រវេសន៍ ដើម្បីបង្កើតទិន្នន័យស្ថិតិរួមស្តីពីទេសន្តរប្រវេសន៍ (២) បង្កើតយន្តការប្រមូលទិន្នន័យទេសន្តរប្រវេសន៍គ្រប់ជ្រុងជ្រោយមួយដែលមានសង្គតិភាព និងត្រូវបានទទួលស្គាល់ដោយថ្នាក់ជាតិ (៣) បង្កើតទិន្នដ្ឋានថ្នាក់ជាតិស្តីពីទេសន្តរប្រវេសន៍ (National Database on Migration) សម្រាប់វិភាគ ផ្សព្វផ្សាយ និងចែករំលែកទិន្នន័យសំខាន់ៗដើម្បីប៉ាន់ប្រមាណនិន្នាការទេសន្តរប្រវេសន៍ និងតម្រូវការកិច្ចសហប្រតិបត្តិការក្នុងការឆ្លើយតបបញ្ហាប្រឈមទាក់ទងនឹងការគ្រប់គ្រងទេសន្តរប្រវេសន៍ (៤) បង្កើតកម្រងទិន្នន័យស្តីពីទេសន្តរប្រវេសន៍កម្ពុជា (Cambodia Migration Profile) សម្រាប់ប្រើប្រាស់ជាមូលដ្ឋានក្នុងការបង្កើតគោលនយោបាយទេសន្តរប្រវេសន៍ផ្អែកលើភស្តុតាង និងទាញយកសេចក្តីសន្និដ្ឋានពាក់ព័ន្ធនឹងអត្ថប្រយោជន៍នៃទេសន្តរប្រវេសន៍ និងផលប៉ះពាល់នៃទេសន្តរប្រវេសន៍លើវិស័យសេដ្ឋកិច្ច បរិស្ថាន និងសង្គម ការចំណាយលើសេវាផ្ទេរប្រាក់ បញ្ហាសុខភាព ការអប់រំ ប្រភេទការងារ និងមុខរបរ ស្ថានភាពរស់នៅ លក្ខខណ្ឌការងារ ប្រាក់ឈ្នួល តម្រូវការរបស់ជនទេសន្តរប្រវេសន៍...។ល។ ដើម្បីធ្វើជាទិន្នន័យបង្អែកសម្រាប់ការរៀបចំនិងអនុវត្តរបៀបវារៈឆ្នាំ២០៣០ ស្តីពីការអភិវឌ្ឍន៍ជាតិប្រកបដោយចីរភាព។ (៥) តាមដាននិងវាយតំលៃគុណភាពប្រព័ន្ធនិងទិន្នន័យដែលបានប្រើប្រាស់។

អាទិភាពដែលត្រូវអនុវត្តសម្រាប់**គោលបំណងទី១១** រួមមានអាទិភាពស្នូលចំនួនបីដែលចាំបាច់ត្រូវពង្រឹង ដើម្បីរួមគ្នាគ្រប់គ្រងលំហូរទេសន្តរប្រវេសន៍ឆ្លងកាត់ព្រំដែនជាមួយប្រទេសជិតខាង និងប្រទេសពាក់ព័ន្ធដោយ "គោរពអធិបតេយ្យភាពជាតិ នីតិរដ្ឋ កាតព្វកិច្ចក្រោមច្បាប់អន្តរជាតិ និងសិទ្ធិរបស់ជនទេសន្តរប្រវេសន៍ទាំងអស់ ដោយមិនគិតពីស្ថានភាពទេសន្តរប្រវេសន៍របស់ពួកគេ ព្រមទាំង

ឆ្លើយតបទៅនឹងស្ថានភាពនៃជនទេសន្តរប្រវេសន៍មានជាអាទិ៍ វ័យ (ជាពិសេសកុមារ) យេនឌ័រ ពិការភាព និងស្ថានភាពឯទៀតដោយគ្មានការរើសអើង”[4]។

អាទិភាពស្នូលទាំងបីគឺ៖ (១) ធានាឱ្យមានរចនាសម្ព័ន្ធ និងយន្តការសមស្របសម្រាប់គ្រប់គ្រងព្រំដែនប្រកបដោយប្រសិទ្ធភាព តាមរយៈនីតិវិធីឆ្លងកាត់ព្រំដែនដែលប្រកបដោយការគោរពសិទ្ធិ និងច្បាប់ជាធរមាន។ (២) បង្កើនកិច្ចសហប្រតិបត្តិការគ្រប់គ្រងព្រំដែន (ឧ. ការកំណត់អត្តសញ្ញាណត្រឹមត្រូវ ការបញ្ជូនបន្តប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា ការផ្តល់ជំនួយ និងកិច្ចការពារសមស្របដល់ជនទេសន្តរប្រវេសន៍ ក្នុងស្ថានភាពងាយរងគ្រោះ) ដោយគោរពអធិបតេយ្យភាពជាតិ នីតិរដ្ឋ កាតព្វកិច្ចផ្លូវច្បាប់អន្តរជាតិ និងសិទ្ធិមនុស្សរបស់ជនទេសន្តរប្រវេសន៍ទាំងអស់។ (៣) ផ្តោតការយកចិត្តទុកដាក់លើកុមារទេសន្តរប្រវេសន៍ដែលចូល/ចេញកម្ពុជាតែម្នាក់ឯង (ដោយពុំមានអ្នកអមដំណើរជាមួយ) ដោយអាជ្ញាធរការពារកុមារត្រូវបានជូនដំណឹងភ្លាមៗ និងចាត់តាំងឱ្យចូលរួមក្នុងនីតិវិធីដោះស្រាយបញ្ហាកុមារ។

ជាចុងក្រោយ **គោលបំណងទី២៣** មានទិសដៅបង្កើនកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយបណ្តាប្រទេសក្នុងតំបន់។ អាទិភាពស្នូលនៃគោលបំណងនេះគឺ ពិនិត្យនិងវាយតម្លៃកិច្ចព្រមព្រៀងទ្វេភាគីនិងពហុភាគីដែលមានស្រាប់ វាយតម្លៃការអនុវត្តកិច្ចព្រមព្រៀងទាំងនោះ និងបង្កើតផែនការសកម្មភាពរួមគ្នាសម្រាប់ការអនុវត្តប្រកបដោយប្រសិទ្ធភាព។ ដោយអនុលោមតាមកតិកាសញ្ញា សកម្មភាពទាំងនេះនឹង "លើកកំពស់ភាពនៃការពង្រឹងគ្នាទៅវិញទៅមក រវាងកតិកាសញ្ញាពិភពលោក និង ក្របខណ្ឌច្បាប់និងគោលនយោបាយអន្តរជាតិនានាដែលមានស្រាប់"។[5]

[4] *គោលបំណង GCM ១១៖ “យើងប្តេជ្ញាគ្រប់គ្រងព្រំដែនជាតិឱ្យមានលក្ខណៈស៊ីសង្វាក់ លើកកម្ពស់កិច្ចសហប្រតិបត្តិការទ្វេភាគី និងថ្នាក់តំបន់ ធានាបានសន្តិសុខសម្រាប់ ប្រទេស សហគមន៍ និងជនទេសន្តរប្រវេសន៍ ព្រមទាំងសម្របសម្រួលសកម្មភាពឆ្លងកាត់ព្រំដែនប្រកបដោយសុវត្ថិភាព និងស្របច្បាប់ ដោយក្នុងពេលជាមួយគ្នាទប់ស្កាត់ទេសន្តរប្រវេសន៍មិនប្រក្រតី។ យើងក៏ប្តេជ្ញាអនុវត្តគោលនយោបាយគ្រប់គ្រងព្រំដែនដែលគោរពអធិបតេយ្យភាពជាតិ នីតិរដ្ឋ កាតព្វកិច្ចក្រោមច្បាប់អន្តរជាតិ និងសិទ្ធិរបស់ជនទេសន្តរប្រវេសន៍ទាំងអស់ ដោយមិនគិតពីស្ថានភាពទេសន្តរប្រវេសន៍របស់ពួកគេ ហើយដោយមិនមានការរើសអើង និងឆ្លើយតបចំពោះចំណុចរសើបផ្នែកយេនឌ័រ និងកុមារ។”*

[5] *គោលបំណង GCM ២៣៖ “យើងប្តេជ្ញាគាំទ្រគ្នាទៅវិញទៅមកដោយយល់ដឹងពីគោលបំណង និងការតាំងចិត្តដែលមាននៅក្នុងកតិកាសញ្ញាពិភពលោកនេះ តាមរយៈការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ ភាពជាដៃគូសកលក្នុងស្មារតីសាមគ្គីភាព ព្រមទាំងបញ្ជាក់បន្ថែមពីសារៈសំខាន់នៃវិធីសាស្ត្រដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងផ្សារភ្ជាប់គ្នា ដើម្បីសម្រួលដល់ទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ និងទទួលស្គាល់ថាយើងទាំងអស់គ្នាជាប្រទេសដើម ប្រទេសឆ្លងកាត់ និងប្រទេសគោលដៅ។ យើងប្តេជ្ញាចាត់វិធានការរួមគ្នាក្នុងការដោះស្រាយបញ្ហាប្រឈមរបស់ប្រទេសនីមួយៗ ដើម្បីអនុវត្តកតិកាសញ្ញាពិភពលោកនេះ គូសបញ្ជាក់ពីបញ្ហាប្រឈមជាក់លាក់ដែលជួបប្រទះ ជាពិសេសប្រទេសអាហ្វ្រិក បណ្តាប្រទេសអភិវឌ្ឍន៍តិចតួច ប្រទេសកំពុងអភិវឌ្ឍន៍គ្មានព្រំដែនជាប់សមុទ្រ រដ្ឋនៃកោះតូចៗកំពុងអភិវឌ្ឍ និងប្រទេសមានប្រាក់ចំណូលមធ្យម។ យើងក៏ប្តេជ្ញាលើកកម្ពស់ការពង្រឹងគ្នាទៅវិញទៅ*

នៅក្នុងគោលបំណងទី២៣នេះ មានអាទិភាពស្នូលចំនួន៥គឺៈ (១) ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជិតខាង ដើម្បីបង្កើនភាពស្របច្បាប់នៃទេសន្តរប្រវេសន៍។ (២) ដោះស្រាយបញ្ហាប្រឈមនៃទេសន្តរប្រវេសន៍តាមរយៈភាពជាដៃគូក្នុងការអនុវត្តកិច្ចព្រមព្រៀង ទ្វេភាគី ថ្នាក់តំបន់ ឬពហុភាគី ផ្អែកលើគោលនយោបាយទេសន្តរប្រវេសន៍ គោលនយោបាយជាតិស្តីពីសុខភាពជនទេសន្តរប្រវេសន៍ និងស្វែងរកឱកាសក្នុងការដោះស្រាយបញ្ហាប្រឈមនានា ដោយអនុលោមតាមទិសដៅនៃកតិកាសញ្ញាពិភពលោក និងច្បាប់អន្តរជាតិ។ (៣) បង្កើនការចូលរួមពីអាជ្ញាធរមូលដ្ឋាន សហជីព វិស័យឯកជន និងសង្គមស៊ីវិល ក្នុងការកំណត់រកតម្រូវការ ឱកាសកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីអនុវត្តកតិកាសញ្ញាពិភពលោកប្រកបដោយប្រសិទ្ធផល។ (៤) បង្កើនកិច្ចការពារពលករទេសន្តរប្រវេសន៍កម្ពុជាធ្វើការនៅក្រៅប្រទេស ដែលបានបញ្ចប់កិច្ចសន្យាការងារ និង/ឬសម្រេចចិត្តវិលត្រឡប់មកកម្ពុជាវិញតាមគោលការណ៍សុវត្ថិភាពទេសន្តរប្រវេសន៍ សម្រាប់ពលករទេសន្តរប្រវេសន៍កម្ពុជាទាំងអស់។ (៥) ផ្តល់កិច្ចការពារយ៉ាងពេញលេញ (ទាំងជនទេសន្តរប្រវេសន៍បរទេសនៅកម្ពុជា និងជនទេសន្តរប្រវេសន៍កម្ពុជាដែលវិលត្រឡប់) ដោយច្បាប់ គោលនយោបាយ និងការអនុវត្តក្រមការងាររបស់កម្ពុជា ច្បាប់ស្តីពីរបបសន្តិសុខសង្គម ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងច្បាប់ស្តីពីអន្តោប្រវេសន៍ ព្រមទាំងយន្តការបណ្តឹង និងអធិការកិច្ច ព្រមទាំងតាមរយៈការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរស្ថាប័ន។

## ការអនុវត្ត ការវាយតម្លៃ និងការធ្វើរបាយការណ៍

ផែនការជាតិនេះ ត្រូវបានរៀបចំសម្រាប់អនុវត្តកតិកាសញ្ញារយៈពេលពីរឆ្នាំ (២០២៤-២០២៦) ដែលក្រសួងស្ថាប័ននីមួយៗ នឹងចូលរួមអនុវត្តទៅតាមវិស័យរបស់ខ្លួន ដោយឆ្លើយតបទៅនឹងសិទ្ធិមនុស្ស បញ្ហាយេនឌ័រ ពិការភាព និងស្ថានភាពផ្សេងទៀត។ រាជរដ្ឋាភិបាលកម្ពុជាទទួលខុសត្រូវដឹកនាំអនុវត្ត ដោយមានការគាំទ្រពីអង្គការ ឬសមាគមដែលជាតំណាងពលករ អង្គការឬសមាគមជាតំណាង

*មករវាងកតិកាសញ្ញាពិភពលោក និង ក្របខ័ណ្ឌច្បាប់អន្តរជាតិ និង គោលនយោបាយនានាដែលមានស្រាប់ តាមរយៈការអនុវត្តកតិកាសញ្ញាពិភពលោកនេះឱ្យស៊ីសង្វាក់គ្នាជាមួយនឹងក្របខ័ណ្ឌផ្សេងៗ ជាពិសេសរបៀបវារៈឆ្នាំ ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព ព្រមទាំងរបៀបវារៈសកម្មភាព Addis Ababa និង ការទទួលស្គាល់ថា ទេសន្តរប្រវេសន៍ និងការអភិវឌ្ឍន៍ប្រកបដោយចីរភាព គឺមានលក្ខណៈពហុផ្នែក និងអាស្រ័យគ្នាទៅវិញទៅមក។”*

និយោជក អង្គការសង្គមស៊ីវិល ក្រុមសិក្សាស្រាវជ្រាវ អង្គការសហប្រជាជាតិជាដើម[6]។ ពលករទេសន្តរប្រវេសន៍នឹងត្រូវបានដាក់បញ្ចូលជាអាទិភាពក្នុងការចូលរួមអនុវត្ត និងវាយតម្លៃនៅគ្រប់ដំណាក់កាល។

រដ្ឋាភិបាលនិងអង្គការអនុវត្ត គួរជួបប្រជុំជាប្រចាំ (គួរកំណត់ក្នុងផែនការសកម្មភាព) ក្នុងកំឡុងពេលនៃការអនុវត្ត ដើម្បីផ្លាស់ប្តូរព័ត៌មានអំពីវឌ្ឍនភាព ដោះស្រាយបញ្ហាប្រឈម និងធានាបានថាការអនុវត្តកំពុងមានដំណើរការទៅមុខ។

នៅចន្លោះរយៈពេលពីរឆ្នាំនៃផែនការនេះ នឹងមានការកំនត់ពេលវេលាសម្រាប់ពិនិត្យ និងវាយតម្លៃ ស្របតាមពេលវេលានៃការវាយតម្លៃថ្នាក់តំបន់ និងវេទិកាវាយតម្លៃទេសន្តរប្រវេសន៍អន្តរជាតិតាមដំណាក់កាលនៃការអនុវត្តផែនការ។ រាជរដ្ឋាភិបាលកម្ពុជានឹងចាត់តាំងតំណាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សជាអ្នកទទួលខុសត្រូវអនុវត្តភារកិច្ចនេះ។ ការពិនិត្យនិងវាយតម្លៃនេះនឹងត្រូវបានចូលរួមផ្តល់ជាតុចូលពីគ្រប់ភាគីពាក់ព័ន្ធ។ គោលបំណងមួយចំនួនទៀតនៃកតិកាសញ្ញានេះនឹងត្រូវបានជ្រើសរើសបន្ថែមដើម្បីដាក់បញ្ចូលទៅក្នុងផែនការជាបន្តបន្ទាប់ ដោយមានកំណត់នូវសកម្មភាពច្បាស់លាស់ សម្រាប់គោលបំណងនីមួយៗ.

## សន្និដ្ឋាន

ការអនុម័តផែនការជាតិសម្រាប់អនុវត្តកតិកាសញ្ញាពិភពលោកស្តីពីទេសន្តរប្រវេសន៍នេះ ពង្រឹងនូវការទទួលស្គាល់របស់រាជរដ្ឋាភិបាលកម្ពុជា នូវភាពពាក់ព័ន្ធនៃបញ្ហាទាក់ទងនឹងទេសន្តរប្រវេសន៍ ព្រមទាំងសបញ្ជាក់ពីការប្តេជ្ញារបស់កម្ពុជា ចំពោះការខិតខំប្រឹងប្រែងឆ្ពោះទៅកាន់វិធីសាស្រ្តផ្តោតលើតម្រូវការគ្រប់វិស័យដើម្បីដោះស្រាយបញ្ហាទេសន្តរប្រវេសន៍។

[6] Whole of government and whole of society approach

| ផែនការជាតិសម្រាប់អនុវត្តកតិកាសញ្ញាពិភពលោកស្តីពីទេសន្តរប្រវេសន៍ រយៈពេលពីរឆ្នាំ (ខែមិថុនា ឆ្នាំ២០២៤ -ខែមិថុនា ឆ្នាំ២០២៦) | | | | | |
|---|---|---|---|---|---|
| យុទ្ធសាស្ត្រអនុវត្តកតិកាសញ្ញា | វិធានការអនុវត្ត | សូចនាករសំខាន់ៗ | ស្ថាប័នអនុវត្ត | ស្ថាប័ន(បន្ថែម)ពាក់ព័ន្ធ | ពេលវេលា |
| **គោលបំណងអាទិភាព** | | | | | |
| គោលបំណងទី១៖ ប្រមូលនិងប្រើប្រាស់ជាមូលដ្ឋាននូវទិន្នន័យដែលសុក្រឹត និងបែងចែកតាមប្រភេទ សម្រាប់ការរៀបចំគោលនយោបាយផ្អែកលើភស្តុតាង | | | | | |
| **អាទិភាពទី១៖** ពង្រឹងកិច្ចសហការរវាងក្រសួងនានា និងធនធានរដ្ឋ ដែលទទួលខុសត្រូវទិន្នន័យផ្សេងៗ ទាក់ទងនឹងទេសន្តរប្រវេសន៍ ដើម្បីបង្កើតទិន្នន័យស្ថិតិរួមស្តីពីទេសន្តរប្រវេសន៍។<br><br>ឧបករណ៍៖ ឧ. របាយការណ៍ព្រំដែន របាយការណ៍ទិដ្ឋាការ ប័ណ្ណស្នាក់នៅ ទិន្នន័យជំរឿន ការស្ទង់មតិអំពីកម្លាំងពលកម្ម ការស្ទង់មតិអំពីសេដ្ឋកិច្ចសង្គម ទិន្នន័យឃុំសង្កាត់។ | **សកម្មភាព ១.១៖** បង្កើត/ពង្រឹងក្រុមការងារបច្ចេកទេសអន្តរក្រសួង ដើម្បីសម្របសម្រួលកិច្ចសហការរវាងក្រសួងនានា។<br><br>**សកម្មភាព ១.២៖** បង្កើតផែនទី និងវាយតម្លៃនូវរាល់ទិន្នន័យទេសន្តរប្រវេសន៍ ដែលមាននៅតាមក្រសួង និងស្ថាប័នពាក់ព័ន្ធនានា ព្រមទាំងពិនិត្យថាតើមានវិធានការអ្វីខ្លះក្នុងការការពារឯកជនភាព។<br><br>**សកម្មភាព ១.៣៖** បង្កើតតួនាទីភារកិច្ច (TORs) ស្តីពីការចែករំលែកទិន្នន័យរវាងក្រសួង សម្រាប់ដាក់បញ្ចូលទៅក្នុងទិន្នដ្ឋានរួមមួយ។ | ក្រុមការងារបច្ចេកទេសត្រូវបានបង្កើតឡើង ហើយដំណើរការពិគ្រោះយោបល់លើកដំបូងត្រូវបានរៀបចំឡើង។ ជាលទ្ធផល យន្តការសហប្រតិបត្តិការរវាងក្រសួងត្រូវបានបង្កើតឡើង។<br><br>ជំរឿនជាតិ មូលដ្ឋានទិន្នន័យឃុំ/សង្កាត់ ជំរឿនជាតិពាក់កណ្តាលអាណត្តិ ទិន្នន័យពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ទិន្នន័យ ពីស្ថានទូត ទិន្នន័យពីក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវៈនីតិសម្បទា...។ល។ ត្រូវបានកំនត់ក្នុងផែនទី | គ.ជ.ប.ជ | • ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ(MoFA)<br>• ក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា (MoSVY)<br>• ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (MoLVT)<br>• ក្រសួងកិច្ចការនារី (MoWA)<br>• ក្រសួងការពារជាតិ (MoD)<br>• ក្រសួងមហាផ្ទៃ (MoI)/អគ្គនាយកដ្ឋានអន្តោប្រវេសន៍ (GDI) អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម (GDID)/អគ្គស្នងការដ្ឋាននគរបាលជាតិ (GCNP) (នាយកដ្ឋានប្រឆាំងភេរវកម្ម និងឧក្រិដ្ឋកម្មឆ្លងដែន/នាយកដ្ឋាន | ឆមាសទី២ ឆ្នាំ ២០២៤ |

| **ផែនការជាតិសម្រាប់អនុវត្តកតិកាសញ្ញាពិភពលោកស្តីពីទេសន្តរប្រវេសន៍ រយៈពេលពីរឆ្នាំ** (ខែមិថុនា ឆ្នាំ២០២៤ -ខែមិថុនា ឆ្នាំ២០២៦) | | | | | |
|---|---|---|---|---|---|
| **យុទ្ធសាស្ត្រអនុវត្តកតិកាសញ្ញា** | **វិធានការអនុវត្ត** | **សូចនាករសំខាន់ៗ** | **ស្ថាប័នអនុវត្ត** | **ស្ថាប័ន(បន្ថែម)ពាក់ព័ន្ធ** | **ពេលវេលា** |
| | | ទិន្នន័យ ហើយ តួនាទីភារកិច្ចស្ថាប័នពាក់ព័ន្ធ ត្រូវបានអនុម័ត។ | | ប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន)<br>• ក្រសួងសុខាភិបាល (MoH)<br>• ក្រសួងផែនការ (MoP)/ វិទ្យាស្ថានជាតិស្ថិតិ (NIS)<br>• ក្រសួងព័ត៌មាន (MoInf.)<br>• បណ្តាញអង្គការសហប្រជាជាតិស្តីពីទេសន្តរប្រវេសន៍<br>• អង្គការក្រៅរដ្ឋាភិបាល<br>• អជ្ញាធរថ្នាក់ក្រោមជាតិ | |
| **អាទិភាពទី២៖** បង្កើតយន្តការប្រមូលទិន្នន័យទេសន្តរប្រវេសន៍គ្រប់ជ្រុងជ្រោយមួយដែលមានសង្គតិភាព និងត្រូវបានទទួលស្គាល់ដោយថ្នាក់ជាតិ។ | **សកម្មភាព ២.១៖** បង្កើតយន្តការ ដើម្បីប្រមូលនិងគ្រប់គ្រងទិន្នន័យ។<br><br>**សកម្មភាព ២**, ពង្រឹងប្រភពទិន្នន័យដើម្បីបង្កើនគុណភាពទិន្នន័យទេសន្តរប្រវេសន៍ការងារថ្នាក់ជាតិរបស់កម្ពុជា។<br><br>**សកម្មភាព ២.៣៖** ពង្រឹង និងកែលម្អការដាក់ជូនជា ប្រចាំឆ្នាំ នូវទិន្នន័យទេសន្តរប្រវេសន៍ការងារកម្ពុជា ដល់មូលដ្ឋាន | ប្រភពទិន្នន័យពាក់ព័ន្ធទាំងអស់ត្រូវបានទទួលស្គាល់ និងដាក់បញ្ចូលក្នុងយន្តការតែមួយកបដោយសង្គតិភាព។<br><br>ភាពចន្លោះប្រហោង ស្តង់ដារ និងវិធីសាស្ត្រ ត្រូវបានពិនិត្យ ឡើងវិញ និងវាយតម្លៃជាប្រព័ន្ធ ដោយមាន | អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ | • ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (MoLVT)<br>• ក្រសួងមហាផ្ទៃ(MoI)/អគ្គនាយដ្ឋានរដ្ឋបាលថ្នាក់ក្រោមជាតិ/អគ្គនាយកដ្ឋានអន្តោប្រវេសន៍(GDI)/អគ្គស្នងការដ្ឋាននគរបាលជាតិ (GCNP) (នាយកដ្ឋាននគរបាលការពារព្រំដែន/ស្នងការដ្ឋាននគរបាលខេត្តជាប់ព្រំដែន) | ឆមាសទី២<br><br>ឆ្នាំទី២ |

| ផែនការជាតិសម្រាប់អនុវត្តកតិកាសញ្ញាពិភពលោកស្តីពីទេសន្តរប្រវេសន៍ រយៈពេលពីរឆ្នាំ (ខែមិថុនា ឆ្នាំ២០២៤ -ខែមិថុនា ឆ្នាំ២០២៦) | | | | | |
|---|---|---|---|---|---|
| យុទ្ធសាស្ត្រអនុវត្តកតិកាសញ្ញា | វិធានការអនុវត្ត | សូចនាករសំខាន់ៗ | ស្ថាប័នអនុវត្ត | ស្ថាប័ន(បន្ថែម)ពាក់ព័ន្ធ | ពេលវេលា |
| | ទិន្នន័យស្ថិតិទេសន្តរប្រវេសន៍ការងារអន្តរជាតិ (ILMS)។ | ជាតុចូល និងការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់។<br><br>គោលបំណងសម្រាប់ការកែលម្អទិន្នន័យត្រូវបានរៀបចំជាសេចក្តីព្រាងសម្រាប់ដាក់បញ្ចូលក្នុងផែនការជាតិ សម្រាប់អនុវត្ត GCM បន្ទាប់។<br><br>ស្ថិតិការងារកម្ពុជាត្រូវបានកែលម្អ និងមានរក្សានៅក្នុង ទិន្នដ្ឋានស្ថិតិទេសន្តរប្រវេសន៍ការងារអន្តរជាតិ | | • ក្រសួងផែនការ(MoP)/នាយកដ្ឋានស្ថិតិ(NIS) | |

| | | | | | |
|---|---|---|---|---|---|
| **អាទិភាពទី៣៖** បង្កើតទិន្នន្ន័យជាតិស្តីពីទេសន្តរប្រវេសន៍ (National Database on Migration) សម្រាប់វិភាគ ផ្សព្វផ្សាយ និងចែករំលែកទិន្នន័យសំខាន់ៗដើម្បីប៉ាន់ប្រមាណនិន្នាការទេសន្តរប្រវេសន៍ និងតម្រូវការកិច្ចសហប្រតិបត្តិការក្នុងការឆ្លើយតបបញ្ហាប្រឈមទាក់ទងនឹងការគ្រប់គ្រងទេសន្តរប្រវេសន៍។ | ^ ៉ ៤្ឫ ២ , បង្កើតទិន្នដ្ឋាន គ្រប់ជ្រុងជ្រោយមួយសម្រាប់គ្រប់គ្រងទិន្នន័យទាក់ទងនឹងទេសន្តរប្រវេសន៍ ដែលគោរពឯកជនភាពនៃទិន្នន័យ និងការពារទិន្នន័យបុគ្គល។<br><br>^ ៉ ៤្ឫ ២ , បញ្ចូលទិន្នន័យដែលមានទាំងអស់ទៅក្នុងមូលដ្ឋានទិន្ន័យរួម ហើយដាក់ដំណើរការជាផ្លូវការ។<br><br>^ ៉ ៤្ឫ ២ , ៖ ប្រមូលទិន្នន័យបែងចែកតាមភេទ និងវិស័យការងារ។<br><br>^ ៉ ៤្ឫ ២ , ពង្រឹងប្រព័ន្ធឌីជីថលសម្រាប់គ្រប់គ្រងទេសន្តរប្រវេសន៍ (ជាពិសេសទេសន្តរប្រវេសន៍ការងារ)។<br><br>^ ៉ ៤្ឫ ២ , បង្កើតតួនាទី និងគោលការណ៍ណែនាំសម្រាប់អ្នកទទួលបន្ទុកគ្រប់គ្រងទិន្នន័យ។ | ទិន្នន័យរួមមានភាពត្រូវគ្នាជាមួយគ្រប់ប្រភពទិន្ន័យទាំងអស់ និងត្រូវគ្រប់គ្រងនៅថ្នាក់អន្តរក្រសួង។<br><br>ទិន្នន័យពាក់ព័ន្ធនឹងពលករ ទេសន្តរប្រវេសន៍ បែងចែកតាមភេទ និងវិស័យការងារ ត្រូវបានចងក្រង។<br><br>ប្រព័ន្ធឌីជីថលសម្រាប់គ្រប់គ្រងពលករទេសន្តរប្រវេសន៍ការងារត្រូវបានពង្រឹង។<br><br>មានគោលការណ៍ណែនាំដែលបញ្ជាក់ពីតួនាទី និងបទដ្ឋានអនុវត្តសម្រាប់អ្នកទទួលបន្ទុកគ្រប់គ្រងទិន្នន័យ។ | អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ | • ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ (MoFA)<br>• ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (MoLVT)<br>• ក្រសួងផែនការ (MoP)/វិទ្យាស្ថានជាតិស្ថិតិ (NIS)<br>• ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា MoSVY<br>• ក្រសួងកិច្ចការនារី(MoWA)<br>• ក្រសួងមហាផ្ទៃ (MoI)/អគ្គនាយកដ្ឋានអន្តោប្រវេសន៍ (GDI)/អគ្គស្នងការដ្ឋាននគរបាលជាតិ(GCNP) (នាយកដ្ឋានប្រឆាំងភេរវកម្ម និងឧក្រិដ្ឋកម្មឆ្លងដែន/នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន)/គ.ជ.ប.ជ | ឆមាសទី២<br><br>ឆ្នាំទី២<br><br><br>កំពុងដំណើរការ |

| **ផែនការជាតិសម្រាប់អនុវត្តកតិកាសញ្ញាពិភពលោកស្តីពីទេសន្តរប្រវេសន៍ រយៈពេលពីរឆ្នាំ** (ខែមិថុនា ឆ្នាំ២០២៤ -ខែមិថុនា ឆ្នាំ២០២៦) | | | | | |
|---|---|---|---|---|---|
| **យុទ្ធសាស្ត្រអនុវត្តកតិកាសញ្ញា** | **វិធានការអនុវត្ត** | **សូចនាករសំខាន់ៗ** | **ស្ថាប័នអនុវត្ត** | **ស្ថាប័ន(បន្ថែម)ពាក់ព័ន្ធ** | **ពេលវេលា** |
| **អាទិភាពទី៤៖** បង្កើតកម្រងទិន្នន័យស្តីពីទេសន្តរប្រវេសន៍កម្ពុជា (Cambodia Migration Profile) សម្រាប់ប្រើប្រាស់ជាមូលដ្ឋានក្នុងការបង្កើតគោលនយោបាយទេសន្តរប្រវេសន៍ផ្អែកលើភស្តុតាង។ | **សកម្មភាព ៤.១៖** លើកកំពស់និងពង្រឹងសមត្ថភាពរបស់អ្នកទទួលបន្ទុកទិន្នន័យរបស់ក្រសួងពាក់ព័ន្ធ ក្នុងការប្រមូល វិភាគ និងប្រើប្រាស់ទិន្នន័យ។<br><br>**សកម្មភាព ៤.២៖** កម្រងទិន្នន័យស្តីពីទេសន្តរប្រវេសន៍កម្ពុជា (Cambodia Migration Profile)ផ្អែកលើចំណេះដឹងពីទិន្នន័យដែលបានពង្រឹងជាប្រព័ន្ធ។ | ស្ថាប័នពាក់ព័ន្ធចូលរួមយ៉ាងសកម្មក្នុងការបង្កើត ការវិភាគ និងការច្របាច់បញ្ចូលគ្នានូវទិន្នន័យ។<br><br>កម្រងទិន្នន័យស្តីពីទេសន្តរប្រវេសន៍កម្ពុជា (Cambodia Migration Profile) ត្រូវបានបញ្ចប់ដោយមានធាតុចូលជាយុទ្ធសាស្ត្រពីស្ថាប័នរដ្ឋនិងសង្គមស៊ីវិលពាក់ព័ន្ធ។ | អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ<br><br>អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ | (ដូចអាទិភាពទី២ខាងលើ) | ឆ្នាំទី២ |
| **អាទិភាពទី៥៖** តាមដាននិងវាយតំលៃគុណភាពប្រព័ន្ធនិងទិន្នន័យដែលបានប្រើប្រាស់។ | **សកម្មភាព ៥.១៖** ធ្វើការវាយតម្លៃ ភាគីពាក់ព័ន្ធទាំងអស់ ទៅលើការអនុវត្តគោលបំណងជាអាទិភាពនៃ GCM ក្នុងបរិបទរបៀបវារៈឆ្នាំ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។ | GCM ត្រូវបានវាយតម្លៃជាមួយនឹងការវាយតម្លៃតាមដំណាក់កាល នូវទិសដៅអភិវឌ្ឍប្រកបដោយចីរភាព។<br><br>គោលបំណងរបស់ GCM ត្រូវបានបញ្ចូលទៅក្នុង | អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ | • ក្រសួងផែនការ(MoP)/វិទ្យាស្ថានជាតិស្ថិតិ (NIS) | ឆមាសទី២ ឆ្នាំទី១ |

| ផែនការជាតិសម្រាប់អនុវត្តកតិកាសញ្ញាពិភពលោកស្តីពីទេសន្តរប្រវេសន៍ រយៈពេលពីរឆ្នាំ (ខែមិថុនា ឆ្នាំ២០២៤ -ខែមិថុនា ឆ្នាំ២០២៦) | | | | | |
|---|---|---|---|---|---|
| **យុទ្ធសាស្ត្រអនុវត្តកតិកាសញ្ញា** | **វិធានការអនុវត្ត** | **សូចនាករសំខាន់ៗ** | **ស្ថាប័នអនុវត្ត** | **ស្ថាប័ន(បន្ថែម)ពាក់ព័ន្ធ** | **ពេលវេលា** |
| | **សកម្មភាព ៥.២៖** កែសម្រួលផែនការសកម្មភាពជាតិដែលពាក់ព័ន្ធ ដោយដាក់បញ្ចូលគោលបំណងរបស់ GCM។ | របៀបវារៈជាតិស្តីពីទិសដៅអភិវឌ្ឍប្រ កបដោយចីរភាព ផែនការអភិវឌ្ឍន៍ជាតិ និងការវាយតម្លៃថ្នាក់ជាតិដោយស្ម័គ្រចិត្ត។ | គ.ជ.ប.ជ | | |
| **គោលបំណងទី១១. គ្រប់គ្រងព្រំដែនរួមគ្នា ដោយសុវត្ថិភាព និងស៊ីសង្វាក់គ្នា** | | | | | |
| **អាទិភាពទី៦៖** ធានាឱ្យមានរចនាសម្ព័ន្ធ និង យន្តការសមស្រប សម្រាប់គ្រប់គ្រងព្រំដែនប្រកបដោយប្រសិទ្ធភាពតាមរយៈនីតិវិធីឆ្លងកាត់ព្រំដែនដែលប្រកបដោយការគោរពសិទ្ធិ និង ច្បាប់ជាធរមាន។ | **សកម្មភាព ៦.១៖** ធ្វើការវាយតម្លៃការគ្រប់គ្រងព្រំដែន សំដៅទៅនីតិវិធី ដោយប្រកាន់ខ្ជាប់គោលការណ៍មិនរើសអើង គោរពសិទ្ធិឯកជនភាព និងការពារទិន្នន័យបុគ្គល (ឧ. ការពិនិត្យអ្នកដំណើរជាមុន របាយការណ៍ពីក្រុមហ៊ុនដឹកជញ្ជូនអ្នកដំណើរ និងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន)។<br><br>**សកម្មភាព ៦.២៖** បង្កើត និងប្រើប្រាស់កម្មវិធីបណ្តុះបណ្តាលជាប្រព័ន្ធ សម្រាប់មន្ត្រីនគរបាលអន្តោប្រវេសន៍ជួរមុខ និងមន្ត្រីនគរបាលព្រំដែន ស្របតាម GCM។ | នីតិវិធីព្រំដែនបច្ចុប្បន្នត្រូវបានវាយតម្លៃ និងកែលម្អតាមជាក់ស្តែង ក្នុងបរិបទនៃសិទ្ធិ និងកិច្ចការពារជនងាយរងគ្រោះ ច្បាប់ស្តីពីសិទ្ធិមនុស្សអន្តរជាតិ ព្រមទាំងកិច្ចព្រមព្រៀង និងឧបករណ៍អន្តរជាតិដទៃទៀត។<br><br>សមត្ថភាពមន្ត្រីព្រំដែនត្រូវបានលើកកំពស់ ដើម្បីពង្រឹងការអនុវត្តនីតិវិធី | ក្រសួងមហាផ្ទៃ/ អគ្គនាយកដ្ឋានអន្តោប្រវេសន៍/ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម / អគ្គស្នងការដ្ឋាននគរបាលជាតិ | | ឆ្នាំទី២ |

| **ផែនការជាតិសម្រាប់អនុវត្តកតិកាសញ្ញាពិភពលោកស្តីពីទេសន្តរប្រវេសន៍ រយៈពេលពីរឆ្នាំ** (ខែមិថុនា ឆ្នាំ២០២៤ -ខែមិថុនា ឆ្នាំ២០២៦) | | | | | |
|---|---|---|---|---|---|
| **យុទ្ធសាស្ត្រអនុវត្តកតិកាសញ្ញា** | **វិធានការអនុវត្ត** | **សូចនាករសំខាន់ៗ** | **ស្ថាប័នអនុវត្ត** | **ស្ថាប័ន(បន្ថែម)ពាក់ព័ន្ធ** | **ពេលវេលា** |
| | **សកម្មភាព ៦.៣៖** គ្រប់គ្រងអន្តរាគមន៍ព្រំដែន និងទប់ស្កាត់ឧក្រិដ្ឋកម្មឆ្លងដែន។<br><br>**សកម្មភាព ៦.៤៖** ពង្រឹងប្រព័ន្ធព័ត៌មានតាម Hotline ដើម្បីដោះស្រាយបញ្ហាទាំងឡាយពាក់ព័ន្ធនឹងទេសន្តរប្រវេសន៍។ | គ្រប់គ្រងព្រំដែនប្រកបដោយប្រសិទ្ធផល។ | | | |
| **យុទ្ធសាស្ត្រទី៧៖** បង្កើនកិច្ចសហប្រតិបត្តិការគ្រប់គ្រងព្រំដែន (ឧ. ការកំណត់អត្តសញ្ញាណត្រឹមត្រូវ ការបញ្ជូនបន្តប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា ការផ្តល់ជំនួយ និងកិច្ចការពារសមស្របដល់ជនទេសន្តរប្រវេសន៍ ក្នុងស្ថានភាពងាយរងគ្រោះ) ដោយគោរពអធិបតេយ្យភាពជាតិ នីតិរដ្ឋ កាតព្វកិច្ចផ្លូវច្បាប់អន្តរជាតិ និងសិទ្ធិមនុស្សរបស់ជនទេសន្តរប្រវេសន៍ទាំងអស់។ | **សកម្មភាព ៧.១៖** បង្កើន/បន្ត/ធានាមានជនបង្គោលសម្រាប់កិច្ចសហប្រតិបត្តិការឆ្លងដែនជាមួយប្រទេសប្រទេសជិតខាង ដោយផ្តោតជាបឋមលើប្រទេសថៃ ម៉ាឡេស៊ី ភូមា វៀតណាម ឡាវ និងចិន។<br><br>**សកម្មភាព ៧.២៖** ពិនិត្យឡើងវិញនិងពង្រឹងនូវនីតិវិធីឆ្លងកាត់ព្រំដែនដែលមានស្រាប់ ដើម្បីធានាវិធានការអនុវត្តមានប្រសិទ្ធិភាព ឆ្លើយតបបញ្ហាយេនឌ័រ ពុំមានការរើសអើង និងស្របតាមស្តង់ដារសិទ្ធិមនុស្សអន្តរជាតិ។ | កិច្ចសហប្រតិបត្តិការឆ្លងកាត់ព្រំដែនជាមួយប្រទេសជិតខាងត្រូវបានបញ្ជូលតាមរយៈការទំនាក់ទំនង និងការផ្លាស់ប្តូរព័ត៌មានជាប្រចាំ។<br><br>នីតិវិធីឆ្លងកាត់ព្រំដែនបច្ចុប្បន្ន ត្រូវបានវាយតម្លៃ និងបង្កើតផែនការសកម្មភាព សម្រាប់កែលម្អការអនុវត្ត។ | ក្រសួងមហាផ្ទៃ/ អគ្គនាយកដ្ឋានអន្តោប្រវេសន៍/ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម/អគ្គស្នងការដ្ឋាននគរបាលជាតិ<br><br>ក្រសួងមហាផ្ទៃ/ អគ្គនាយកដ្ឋានអន្តោប្រវេសន៍/ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម/អគ្គស្នងការដ្ឋាននគរបាលជាតិ | • អាជ្ញាធរថ្នាក់ក្រោមជាតិ<br>• ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ (MoFAIC) | ឆ្នាំទី១ |

| ផែនការជាតិសម្រាប់អនុវត្តកតិកាសញ្ញាពិភពលោកស្តីពីទេសន្តរប្រវេសន៍ រយៈពេលពីរឆ្នាំ (ខែមិថុនា ឆ្នាំ២០២៤ -ខែមិថុនា ឆ្នាំ២០២៦) | | | | | |
|---|---|---|---|---|---|
| យុទ្ធសាស្ត្រអនុវត្តកតិកាសញ្ញា | វិធានការអនុវត្ត | សូចនាករសំខាន់ៗ | ស្ថាប័នអនុវត្ត | ស្ថាប័ន(បន្ថែម)ពាក់ព័ន្ធ | ពេលវេលា |
| | **សកម្មភាព ៧.៣៖** កសាងសមត្ថភាពមន្ត្រីការិយាល័យទំនាក់ទំនងព្រំដែនកម្ពុជា-ថៃ លើផ្នែកគ្រប់គ្រងព្រំដែន និងទំនាក់ទំនងអន្តរជាតិ។ | | ក្រសួងមហាផ្ទៃ/ អគ្គនាយកដ្ឋានអន្តោប្រវេសន៍/ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម/អគ្គស្នងការដ្ឋាននគរបាលជាតិ | | |
| | **សកម្មភាព ៧.៤៖** ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីផ្លាស់ប្តូរព័ត៌មាន និងបទពិសោធន៍ ពាក់ព័ន្ធនឹងការគ្រប់គ្រងព្រំដែន និងទេសន្តរប្រវេសន៍។ | | អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ | | |
| | **សកម្មភាព ៧.៥៖** បង្កើតការិយាល័យទំនាក់ទំនង ព្រំដែនកម្ពុជា-ឡាវ និងការិយាល័យទំនាក់ទំនងព្រំដែន កម្ពុជា-វៀតណាម។ | | អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ | | |

| | | | | | |
|---|---|---|---|---|---|
| **អាទិភាពទី៨៖** ផ្តោតការយកចិត្តទុកដាក់លើកុមារទេសន្តរប្រវេសន៍ដែលចូល/ចេញកម្ពុជាតែម្នាក់ឯង (ដោយពុំមានអ្នកអមដំណើរជាមួយ) ដោយអាជ្ញាធរការពារកុមារត្រូវបានជូនដំណឹងភ្លាមៗ និងចាត់តាំងឱ្យចូលរួមក្នុងនីតិវិធីដោះស្រាយបញ្ហាកុមារ។ | **សកម្មភាព ៨.១៖** ធ្វើការវាយតម្លៃគោលនយោបាយព្រំដែន និងកែសម្រួល SOP ដើម្បីធានាថា យន្តការការពារកុមារត្រូវបានដាក់បញ្ចូលនៅគ្រប់កម្រិតនៃការងារគ្រប់គ្រងព្រំដែន។ | សមត្ថភាពមន្ត្រីព្រំដែនក្នុងការកំណត់អត្តសញ្ញាណ និងការពារកុមារដែលពុំមានអ្នករួមដំណើរជាមួយ ឬកុមារធ្វើដំណើរតែម្នាក់ឯង ត្រូវបានលើកកំពស់។ | ក្រសួងមហាផ្ទៃ/ អគ្គនាយកដ្ឋានអន្តោរប្រវេសន៍/ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម/ អគ្គស្នងការដ្ឋាននគរបាលជាតិ | | ឆ្នាំទី២ |
| **គោលបំណងទី២៣. ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងភាពជាដៃគូសកល សម្រាប់ទេសន្តរប្រវេសន៍ ប្រកបដោយសុវត្ថិភាព របៀបរយ និងស្របច្បាប់** | | | | | |
| **អាទិភាពទី៩៖** ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជិតខាង ដើម្បីបង្កើនភាពស្របច្បាប់នៃទេសន្តរប្រវេសន៍។ | **សកម្មភាព ៩.១៖** ពិនិត្យឡើងវិញនិងធ្វើបច្ចុប្បន្នភាពជាប្រព័ន្ធ ទៅលើគោលនយោបាយ កិច្ចព្រមព្រៀង និងយន្តការដែលមានស្រាប់ទាំងអស់ ក្នុងទិសដៅពង្រឹងមាគ៌ាទេសន្តរប្រវេសន៍ស្របច្បាប់ និងអនុលោមតាមច្បាប់អន្តរជាតិ។<br><br>**សកម្មភាព ៩.២៖** ធ្វើការវាយតម្លៃច្បាស់លាស់ ទៅលើលទ្ធភាពទេសន្តរប្រវេសន៍ស្របច្បាប់ និងផលប៉ះពាល់នៃទេសន្តរប្រវេសន៍មិនស្របច្បាប់ តាមរយៈកិច្ចសហប្រតិបត្តិការជាមួយសហជីព វិស័យ | កិច្ចព្រមព្រៀង MOUs និង SOPs ដែលមានស្រាប់ត្រូវបានពិនិត្យឡើងវិញតាម រយៈដំណើរការអន្តរក្រសួងក្នុងបរិបទនៃព្រឹត្តិការណ៍បច្ចុប្បន្ន រួមទាំង បរិបទ COVID-19 ហើយជាលទ្ធផល បង្កើតបានជាផែនការសកម្មភាពដើម្បីពង្រឹងការអនុវត្ត ព្រមទាំងយុទ្ធសាស្ត្រយុទ្ធនាការជាតិដើម្បីលើកកម្ពស់ការយល់ដឹង។ | ក្រសួងមហាផ្ទៃ/ អគ្គនាយកដ្ឋានអន្តោរប្រវេសន៍/ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម/ អគ្គស្នងការដ្ឋាននគរបាលជាតិ | • ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (MoLVT)<br>• ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ (MoFAIC)<br>• ក្រសួងសុខាភិបាល (MoH)<br>• ក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា (MoSVY)<br>• ក្រសួងការពារជាតិ (MoD)<br>• ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MoEF) | ឆមាសទី១ ឆ្នាំទី១ |

| | | | | | |
|---|---|---|---|---|---|
| | ឯកជន សង្គមស៊ីវិល និងអ្នកពាក់ព័ន្ធអន្តរជាតិសំខាន់ៗ។ | | | • បណ្តាញអង្គការសហប្រជាជាតិស្តីពីទេសន្តរប្រវេសន៍<br>• អង្គការក្រៅរដ្ឋាភិបាល | |
| **អាទិភាពទី១០៖** ដោះស្រាយបញ្ហាប្រឈមនៃទេសន្តរប្រវេសន៍តាមរយៈភាពជាដៃគូក្នុងការអនុវត្តកិច្ចព្រមព្រៀង ទ្វេភាគី ថ្នាក់តំបន់ ឬពហុភាគី ផ្អែកលើគោលនយោបាយទេសន្តរប្រវេសន៍ គោលនយោបាយជាតិស្តីពីសុខភាពជនទេសន្តរប្រវេសន៍ និងស្វែងរកឱកាសក្នុងការដោះស្រាយបញ្ហាប្រឈមនានា ដោយអនុលោមតាមទិសដៅនៃកតិកាសញ្ញាពិភពលោក និងច្បាប់អន្តរជាតិ។ | **សកម្មភាព ១០.១៖** ធ្វើការពិនិត្យឡើងវិញជាលក្ខណៈអន្តរក្រសួង ដែលមានការចូលរួមពីសហជីព វិស័យឯកជន សង្គមស៊ីវិល និងអ្នកពាក់ព័ន្ធអន្តរជាតិសំខាន់ៗ ដើម្បីវាយតម្លៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី និងពហុភាគីដែលមានស្រាប់ទាំងអស់ (ឧ. COMMIT, MOUs ជាមួយប្រទេសថៃ ប្រទេសម៉ាឡេស៊ី ប្រទេសចិន)។<br><br>**សកម្មភាព ១០.២៖** បង្កើតផែនការសកម្មភាពរួមគ្នាជាមួយស្ថាប័នអន្តរជាតិដើម្បីអនុវត្តកិច្ចព្រមព្រៀងអន្តរជាតិដែលមានស្រាប់ឱ្យកាន់តែមានប្រសិទ្ធផល។<br><br>**សកម្មភាព ១០.៣៖** ធ្វើការពិនិត្យឡើងវិញ ជាលក្ខណៈអន្តរក្រសួង ដែលមានការចូលរួមពីសង្គមស៊ីវិល សហជីព និងវិស័យឯកជន (ព្រមទាំង ភ្នាក់ងារជ្រើសរើសពលករ) និង អ្នកពាក់ព័ន្ធអន្តរជាតិសំខាន់ៗ ដើម្បីកែលម្អ និងធ្វើបច្ចុប្បន្ន | ការអនុវត្តកិច្ចព្រមព្រៀង MOUs និង SOPs ដែលមានស្រាប់ ត្រូវបានពង្រឹងតាមរយៈការសន្ទនាជាលក្ខណៈពហុភាគី ជាមួយប្រទេសពាក់ព័ន្ធ។<br><br>អំពើកេងប្រវ័ញ្ចចំពោះពលករទេសន្តរប្រវេសន៍នៅក្នុងដំណាក់កាលជ្រើសរើស ត្រូវបានពិនិត្យឡើងវិញ និងកាត់បន្ថយ តាមរយៈការពង្រឹងដំណើរការបណ្តុះបណ្តាលសម្រាប់ពលករ និងការបង្កើនការយល់ដឹងអំពីការកេងប្រវ័ញ្ច។ | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ<br><br>ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ<br><br>ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | • ក្រសួងកិច្ចការនារី (MoWA)<br>• ក្រសួងមហាផ្ទៃ (MoI)<br>• អាជ្ញាធរថ្នាក់ក្រោមជាតិ<br>• ក្រសួងសុខាភិបាល (MoH)<br>• ទីភ្នាក់ងារជ្រើសរើសពលករ<br>• បណ្តាញអង្គការសហប្រជាជាតិស្តីពីទេសន្តរប្រវេសន៍<br>• អង្គការក្រៅរដ្ឋាភិបាល | ឆ្នាំទី២ |

| | | | | | |
|---|---|---|---|---|---|
| | ភាពការអនុវត្តការងាររបស់ភ្នាក់ងារជ្រើសរើសពលករទេសន្តរប្រវេសន៍។<br><br>**សកម្មភាព ១០.៤៖** បង្កើតផែនការសកម្មភាពរួមគ្នា ជាមួយប្រទេសថៃ ម៉ាឡេស៊ី និងប្រទេសគោលដៅដទៃទៀត ដើម្បីតាមដាននិងវាយតម្លៃ យុទ្ធសាស្ត្រជ្រើសរើសពលករនៃវិស័យឯកជន។ | | ក្រសួងការងារ/គ.ជ.ប.ជ | | |
| **អាទិភាពទី១១៖** បង្កើនការចូលរួមពីអាជ្ញាធរមូលដ្ឋាន សហជីព វិស័យឯកជន និងសង្គមស៊ីវិល ក្នុងការកំណត់រកតម្រូវការ ឱកាសកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីអនុវត្តកតិកាសញ្ញាពិភពលោកប្រកបដោយប្រសិទ្ធផល។ | **សកម្មភាព ១១.១៖** សហការ និងចូលរួមជាមួយអាជ្ញាធរមូលដ្ឋាន និងសង្គមស៊ីវិលពាក់ព័ន្ធដើម្បីដាក់បញ្ចូលទស្សនៈ និងអាទិភាពរបស់ស្ថាប័នពួកគេ ទៅក្នុងកិច្ចការធ្វើឱ្យស្របច្បាប់នូវការបញ្ជូនត្រឡប់នៃពលករទេសន្តរប្រវេសន៍កម្ពុជាតាមរយៈគោលនយោបាយ និង SOP ដែលបានកែសម្រួល។ | វិធានការទប់ស្កាត់ និងកាត់បន្ថយអំពើពុករលួយពាក់ព័ន្ធនឹងការឆ្លងដែនមិនស្របច្បាប់ ត្រូវបានបង្កើត និង/ឬពង្រឹង។ | ក្រសួងមហាផ្ទៃ/ អគ្គនាយកដ្ឋានអន្តោប្រវេសន៍/ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម/អគ្គស្នងការ ដ្ឋាននគរបាលជាតិ | | ឆមាសទី២ ឆ្នាំទី១ |
| **អាទិភាពទី១២៖** បង្កើនកិច្ចការពារពលករទេសន្តរប្រវេសន៍កម្ពុជាធ្វើការនៅក្រៅប្រទេស ដែលបានបញ្ចប់កិច្ចសន្យាការងារ និង/ឬសម្រេចចិត្តវិលត្រឡប់មកកម្ពុជាវិញ តាមគោលការណ៍សុវត្ថិភាពទេសន្តរប្រវេសន៍ | **សកម្មភាព ១២.១៖** រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយប្រទេសថៃ ស្តីពីនីតិវិធីវិលត្រឡប់សុវត្ថិភាព សម្រាប់ពលករទេសន្តរប្រវេសន៍ត្រឡប់មកប្រទេសកម្ពុជាវិញ។ | ការសន្ទនាជាមួយប្រទេសគោលដៅត្រូវបានរៀបចំឡើង សម្រាប់ការផ្ទេរអត្ថប្រយោជន៍ដោយប្រសិទ្ធភាព។ | គ.ជ.ប.ជ (ក្រសួងមហាផ្ទៃ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសង្គមកិច្ច | ក្រុមការងារទេសន្តរប្រវេសន៍ | ដំណើរការបន្ត |

| | | | | | |
|---|---|---|---|---|---|
| សម្រាប់ពលករទេសន្តរប្រវេសន៍កម្ពុជាទាំងអស់។ | **សកម្មភាព ១២.២៖** បង្កើត SOP ទ្វេភាគីជាមួយរដ្ឋាភិបាលថៃ ដើម្បីធានានូវការវិលត្រឡប់ដោយសុវត្ថិភាព នៃពលករទេសន្តរប្រវេសន៍។<br><br>**សកម្មភាព ១២.៣៖** ចូលរួមក្នុង CLMT និង ASEAN ដើម្បីលើកកម្ពស់ចល័តភាពនៃអត្ថប្រយោជន៍សន្តិសុខសង្គម ដោយមានធាតុចូលពីដំណើរការអនុវត្ត GCM។<br><br>**សកម្មភាព ១២.៤៖** បង្កើតនិងពង្រឹងយន្តការមាតុភូមិនិវត្ត សមាហរណកម្ម និងស្តារនីតិសម្បទា នៃជនទេសន្តរប្រវេសន៍រងគ្រោះ។ | លទ្ធផលនៃកិច្ចពិគ្រោះយោបល់ | អតីតយុទ្ធជន និងយុវនីតិសម្បទា<br><br>គ.ជ.ប.ជ (ក្រសួងមហាផ្ទៃ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។<br><br>ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ក្រុមការងារទេសន្តរប្រវេសន៍<br><br>អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ក្រុមការងារកិច្ចការពារជនរងគ្រោះ | |
| **អាទិភាពទី១៣៖** ផ្តល់កិច្ចការពារយ៉ាងពេញលេញ (ទាំងជនទេសន្តរប្រវេសន៍បរទេសនៅកម្ពុជា និងជនទេសន្តរប្រវេសន៍កម្ពុជាដែលវិលត្រឡប់) ដោយច្បាប់ គោលនយោបាយ និងការអនុវត្តក្រមការងាររបស់កម្ពុជា ច្បាប់ស្តីពីរបបសន្តិសុខសង្គម ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស | **សកម្មភាព ១៣.១៖** ពិនិត្យឡើងវិញនូវច្បាប់ពាក់ព័ន្ធនឹងជនទេសន្តរប្រវេសន៍ដែលចូលមកកម្ពុជា ក្នុងគោលបំណងបំពេញរាល់ចន្លោះប្រហោងនានា ព្រមទាំងធានានូវការការពារពេញលេញ ផ្នែកការងារ និងសង្គម។ | អធិការកិច្ចការងារចាប់ផ្តើមគ្របដណ្តប់លើកន្លែងការងារ ដែលមានជបរទេសក្នុងប្រទេសកម្ពុជា។ កិច្ចប្រជុំសម្របសម្រួលអន្តរក្រសួងត្រូវបានរៀបចំឡើងមួយឆ្នាំម្តង។ | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | • ក្រសួងមហាផ្ទៃ (MoI)<br>• ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ (MoFAIC)<br>• ក្រសួងសុខាភិបាល (MoH)<br>• ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (MoSVY) | ដំណើរការបន្ត |

| | | | | | |
|---|---|---|---|---|---|
| និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងច្បាប់ស្តីពីអន្តោប្រវេសន៍ ព្រមទាំងយន្តការបណ្តឹង និងអធិការកិច្ច ព្រមទាំង តាមរយៈការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរស្ថាប័ន។ | **សកម្មភាព ១៣.២៖** ធានាការអនុវត្តក្របខ័ណ្ឌច្បាប់របស់កម្ពុជា តាមរយៈការធ្វើអធិការកិច្ចការងារ និងផ្នែកផ្សេងៗទៀត ព្រមទាំងទណ្ឌកម្មសមស្រប ដើម្បីឱ្យជនទេសន្តរប្រវេសន៍ដែលចូលមក កម្ពុជាអាចទទួលបានយន្តការផ្តល់យុត្តិធម៌ដល់អំពើជួញដូរ ការរំលោភបំពានការងារពលកម្មដោយបង្ខំ និងការរំលោភបំពានផ្សេងៗទៀត។ | | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | • ក្រសួងព័ត៌មាន (MoInf.)<br>• ក្រសួងការពារជាតិ (MoD)<br>• ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MoEF)<br>• បណ្តាញអង្គការសហប្រជាជាតិស្តីពីទេសន្តរប្រវេសន៍<br>• អង្គការក្រៅរដ្ឋាភិបាល<br>• ក្រុមការងារទេសន្តរប្រវេសន៍ | |
| | **សកម្មភាព ១៣.៣៖** បង្កើតគណៈកម្មាធិការសម្របសម្រួលអន្តរក្រសួង ដើម្បីពិភាក្សាអំពីទេសន្តរប្រវេសន៍ចូលមកកម្ពុជា ហើយធានាថា បញ្ហាថ្មីៗដែលនឹងកើតឡើង ទាក់ទងនឹងការការពារ និងច្បាប់ នឹងត្រូវបានដោះស្រាយ។ ធ្វើការត្រួតពិនិត្យឡើងវិញនូវការអនុវត្តច្បាប់។ | | គ.ជ.ប.ជ | | |
| | **សកម្មភាព ១៣.៤៖** បង្កើតនិងពង្រឹងយន្តការមាតុភូមិនិវត្តនៃជនរងគ្រោះដែលបានទេសន្តរប្រវេសន៍មកកម្ពុជា ទៅកាន់ប្រទេសកំណើតរបស់ពួកគេវិញ។ | | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ក្រសួងការបរទេស អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ក្រុមការងារកិច្ចការពារជនរងគ្រោះ អគ្គស្នងការដ្ឋាននគរបាលជាតិ | |

# Royal Government of Cambodia

# National Implementation Plan

## Global Compact for Safe, Orderly and Regular Migration (GCM)

## Introduction

The Global Compact for Safe, Orderly and Regular Migration (GCM) was approved by the General Assembly of the United Nations on 19 December 2018 (Resolution A/RES/73/195). The Compact is based on 10 guiding principles which promote a holistic approach to migration that demands the involvement of all levels of national government, trade unions, private sector, civil society, and the United Nations. These principles are reflected in the 23 objectives of the Compact, which are encouraged to be implemented through individual national plans (paragraph 53).

In accordance with the GCM, the International Migration Review Forum (IMRF)[7] have served as the primary intergovernmental platform to discuss, share, and evaluate the implementation of the 23 objectives at a global level. The IMRF shall take place every four years and result in an intergovernmental Progress Declaration in each instance. The first IMRF was held in May 2022.

